**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៦០ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយ ដែលមានសមាសភាពដូចខាងក្រោម៖

១. លោកជំទាវវេជ្ជ. **យក់ សម្បត្តិ** រដ្ឋលេខាធិការប្រចាំការក្រសួងសុខាភិបាល ប្រធាន

| | | | |
|---|---|---|---|
| ២. ឯកឧត្តម | **សេន សុខណ្ណា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. ឯកឧត្តមវេជ្ជ. | **ស៊ុខ ទិនផះ** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤. លោកជំទាវ | **ទិន លីណា** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធាន |
| ៥. ឯកឧត្តម | **សុខ សំអោទ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល | សមាជិក |
| ៦. ឯកឧត្តមវេជ្ជ. | **ហុក គឹមចេង** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសុខាភិបាល | សមាជិក |
| ៧. ឯកឧត្តមវេជ្ជ. | **លី សូវ៉ាន់** | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសុខាភិបាល | សមាជិក |
| ៨. តំណាងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) | | | សមាជិក |
| ៩. តំណាងអង្គការសុខភាពពិភពលោក | | | សមាជិក |
| ១០. តំណាងអាជ្ញាធរដែនដី និងផ្នែកពាក់ព័ន្ធ | | | សមាជិក។ |

**ប្រការ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលក្នុងការទប់ស្កាត់ និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងសុខភាពតែមួយ (One Health) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ខិតខំប្រឹងប្រែងស្វែងរកការគាំទ្រក្នុងការផ្តល់អាទិភាពលើផ្នែកនានានៃសុខភាពតែមួយ រួមមានភាពស៊ាំនឹងថ្នាំផ្សះ សុវត្ថិភាពចំណីអាហារ ជំងឺបង្កឡើងដោយសត្វ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត
- ពិនិត្យឡើងវិញឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងផ្នែកនានា នៃសុខភាពតែមួយ រួមមានភាពស៊ាំនឹងថ្នាំផ្សះ សុវត្ថិភាពចំណីអាហារ ជំងឺបង្កឡើងដោយសត្វ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត សម្រាប់ការធ្វើឱ្យប្រសើរឡើងនៃការអនុវត្ត
- ធ្វើសុខដុមនីយកម្មយុទ្ធសាស្ត្រជាតិដែលមានស្រាប់ពាក់ព័ន្ធនឹងសុខភាពតែមួយ
- ធ្វើឱ្យប្រសើរឡើងគំរូនៃយន្តការសម្របសម្រួលលើការអភិវឌ្ឍន៍ និងការអនុវត្តកម្មវិធីក្នុងផ្នែកនានានៃសុខភាពតែមួយ រួមមានភាពស៊ាំនឹងថ្នាំផ្សះ សុវត្ថិភាពចំណីអាហារ ជំងឺបង្កឡើងដោយសត្វ ក្នុងការកំណត់អត្តសញ្ញាណ អាទិភាព និងយុទ្ធសាស្ត្រ
- ធានានូវអាទិភាពគន្លឹះសុខភាពតែមួយ ដែលត្រូវបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣
- តាមដានការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសុខភាពតែមួយ រួមមានភាពស៊ាំនឹងថ្នាំផ្សះ សុវត្ថិភាពចំណីអាហារ ជំងឺបង្កឡើងដោយសត្វ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត រួមទាំងការធ្វើសុខដុមនីយកម្ម និងសង្គតភាពនៃអន្តរាគមន៍ ដើម្បីគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចក្ខុវិស័យរយៈពេលវែងនៃយុទ្ធសាស្ត្រសុខភាពតែមួយ
- ផ្តល់ការសម្របសម្រួលផ្នែកបច្ចេកទេសលើការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពតែមួយ រួមមានភាពស៊ាំនឹងថ្នាំផ្សះ សុវត្ថិភាពចំណីអាហារ ជំងឺបង្កឡើងដោយសត្វ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត ជាមួយនឹងវិធីសាស្ត្ររួមចំពោះសមភាពយេនឌ័រ និរន្តរភាពបរិស្ថាន សមធម៌សង្គម និងការផ្លាស់ប្តូរអាកប្បកិរិយា
- ទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិ ឬក្រុមការងារបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត
- បង្កើតសូចនាករត្រួតពិនិត្យរួមស្តីពីការកសាងសមត្ថភាពគណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយ

- បង្កើតផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍វឌ្ឍនភាពរាយការណ៍ជូនរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍអនុលោមតាមសូចនាករត្រួតពិនិត្យរួម និងទស្សនៈសុខដុមនីយកម្ម សង្គតភាព និងលទ្ធផលនៃផែនការសកម្មភាព
- ផ្តល់យោបល់លើរបាយការណ៍វឌ្ឍនភាពរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចូលរួមក្នុងការពង្រឹងខ្លឹមសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- សម្របសម្រួលជាមួយអាជ្ញាធរដែនដី និងផ្នែកពាក់ព័ន្ធ
- បំពេញភារកិច្ចចាំបាច់ពាក់ព័ន្ធផ្សេងទៀត។

**ប្រការ៣ :** គណៈកម្មការអន្តរក្រសួងនេះ អាចបង្កើតអនុគណៈកម្មការ ឬក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដើម្បីគាំទ្រដល់ការអនុវត្តការងាររបស់ខ្លួន។

**ប្រការ៤ :** អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានដែលទទួលបានការប្រគល់សិទ្ធិពីប្រធាន អាចកោះប្រជុំ និង/ឬដឹកនាំកិច្ចប្រជុំជំនួសបាន។

**ប្រការ៥ :** គណៈកម្មការអន្តរក្រសួងនេះ ប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ដើម្បីបំពេញការងាររបស់ខ្លួន។

**ប្រការ៦ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ